# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែកក្កដា ឆ្នាំ២០១៥

*នៅក្នុងខែកក្កដា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើក និងសម័យប្រជុំពេញអង្គចំនួន០៣លើក*

*-អញ្ជើញចូលរួមជាកិត្តិយស និងអមព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ក្នុងកម្មវិធីបុណ្យរុក្ខទិវា ០៩ កក្កដា ឆ្នាំ២០១៥ នៅក្នុងខេត្តកំពង់ធំ*

*-អញ្ជើញដឹកនាំអង្គប្រជុំរៀបចំតួនាទី ភារកិច្ច ដល់ទីប្រឹក្សា និងជំនួយការសម្តេចប្រធាន*

*-អនុញ្ញាតឲ្យឯកឧត្តម* Han Qide *អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ធ្វើសវនាការ*

*-អនុញ្ញាតឲ្យឯកឧត្តម* Thomas GAMBKE *ប្រធានក្រុមសមាជិកសភាអាល្លឺម៉ង់ ធ្វើសវនាការ*

*-អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខ អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ និងប្រជាជន ស្រុកសណ្តាន់ ខេត្តកំពង់ធំ និងចុះសួរសុខទុក្ខអភិរក្សព្រៃឡង់*

*-អញ្ជើញចុះសាកសួរសុខទុក្ខ មន្ត្រី និងអាជ្ញាធរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចុះសាកសួរសុខទុក្ខគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា សិស្សានុសិស្ស នៅវិទ្យាល័យព្រះស៊ីសុវត្ថិ

-អញ្ជើញចូលរួមពិធីបុណ្យសព និងផ្តល់កិត្តិយសប្រទានភ្លើងបូជាសពឯកឧត្តម **ខ្ជួត រ៉ាន់ឌី** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា

-អញ្ជើញនាំយកទៀនព្រះវស្សា ទេយ្យវត្ថុ អង្ករ គ្រឿងឧបភោគ ប្រគេន **សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបុទុមវត្តី រាជធានីភ្នំពេញ

-អញ្ជើញចុះបំពេញការងារមូលដ្ឋានចំនួន០៣លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៩៦ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ឬាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញជាអធិបតីភាពក្នុងពិធីបើកកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៥ ដើម្បីលើកគម្រោងរៀបចំវេទិកាភូមិភាគទី៥

-អញ្ជើញចុះបំពេញការងារមូលដ្ឋានក្នុងរាជធានី-ខេត្តចំនួន០៣លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាឬាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងទិវាមច្ឆាជាតិ ១កក្កដា២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅអាងទឹកខ្នាច ភូមិវត្ត ឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅជួបសំណេះសំណាល និងពិនិត្យព្យាបាល

ជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋ នៅឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-អញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងចែកអំណោយដល់សិស្សានុសិស្ស ព្រមទាំងផ្តល់ថវិកាសម្រាប់ទិញដីចាក់បំពេញទីធ្លាសាលា ជួសជុលអណ្តូងស្នប់មួយ និងទិញម៉ូទ័របូមទឹកដាក់សាលាបឋមសិក្សាកំពង់តាឡុង ស្ថិតនៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើកដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០២ និងសេចក្តីស្នើច្បាប់ចំនួន០១ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

២.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីកតិសន្យាពិសេស

៣.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

៤.ពិនិត្យ និងសម្រេចលើសំណើលេខ:៤៤/១៥ លគ.គក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ របស់គណបក្សប្រជាជនកម្ពុជា

៥.ស្តាប់របាយការណ៍របស់គណៈកម្មការពិសេស ស្តីពីលទ្ធផលនៃការពិនិត្យសិក្សា និងរៀបចំសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា

៦.កំណត់កាលបរិច្ឆេទ និងរបៀបវារៈបន្តសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើកដើម្បី៖**

១.បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការសាសនា វប្បធម៌ វិចិត្រសិល្ប: និងទេសចរណ៍ នៃព្រឹទ្ធសភា

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ

សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

៣.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីកតិសន្យាពិសេស

៤.ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី

៥.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកក្កដានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងរាស្ត្រហត្ថលេខីរបស់រដ្ឋសភា ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០២ និងសេចក្តីស្នើច្បាប់ចំនួន០១ ។

-ប្រជុំពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន១៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន២២ករណី ទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ចំនួន០១ករណី និងអភិបាលខេត្តកំពង់ស្ពឺចំនួន០១ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០៣ករណី ។

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីឆ្លងខ្លឹមសារ និងកម្មវិធីរៀបចំវេទិកាថ្នាក់ស្រុក នៅស្រុកកំចាយមារ និងស្រុកកញ្ជៀច ក្នុងខេត្តព្រៃវែង និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ស្តីពីគម្រោងរៀបចំវេទិកា នៅភូមិភាគទី៥

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីពិនិត្យ និងពិភាក្សាផែនការប្រតិបត្តិប្រចាំឆមាសទី២ ឆ្នាំ២០១៥ និងកំណត់ពេលវេលាចុះតាមដានពីលទ្ធផលក្រោយរៀបចំវេទិកាក្រុមសមាជិកភូមិភាគទី៣

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់អាមេរិកទៅទស្សនកិច្ចសិក្សា និងស្វែងយល់អំពី

ការរីកចម្រើនវិស័យកសិកម្ម និងឧស្សាហកម្ម និងចុះពិនិត្យ ព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅក្នុងបរិវេណគ្លីនិកទីក្រុងកំពុងផែឧកញ៉ាម៉ុង

-ចូលរួមកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ាលើកទី៧ នៅខេត្តសៀមរាប

-ជួបពិភាក្សាការងារជាមួយលោកជំទាវ ជូ ប៊ុនចាន់ រដ្ឋលេខាធិការក្រសួងមហាផ្ទៃអំពីបញ្ហាស្ត្រីធ្វើទេសន្តប្រវេសន៍នៅប្រទេសថៃ និងប្រទេសនានា

-ជួបជាមួយថ្នាក់ដឹកនាំខេត្តស្ទឹងត្រែងទទួលបន្ទុកកម្មវិធីអភិវឌ្ឍតំបន់ត្រីកោណ (CLV) ។

-រៀបចំសិក្ខាសាលាស្តីពី " គំរូ និងបែបបទនៃដំណើរការរបស់ការិយាល័យថវិកាសភា (PBO) " ដើម្បីផ្សព្វផ្សាយលទ្ធផល នៃទស្សនកិច្ចសិក្សារបស់គណៈប្រតិភូសមាជិកសភាកម្ពុជានៅរដ្ឋសភាប្រទេសស៊ុយអ៊ែត ហ្វាំងឡង់ និងវៀតណាម

-ចូលរួមសិក្ខាសាលាស្តីពី " សេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល " , "ផលប៉ះពាល់ និងការអនុវត្តនៃបម្រែបម្រួលអាកាសធាតុ យុទ្ធសាស្ត្រ និងសន្តិសុខសម្រាប់ប្រទេសសមាជិកអាស៊ាន" និងសិក្ខាសាលាស្តីពី "លទ្ធិប្រជាធិបតេយ្យសេរីនិយម

-ចូលរួមស្តាប់បទបង្ហាញរបស់វិទ្យាស្ថានសភាកម្ពុជា PIC ស្តីពី "មូលហេតុនៃភាពក្រីក្រ និងគោលនយោបាយពាក់ព័ន្ធនៅទីជនបទនៃប្រទេសកម្ពុជា

-អនុញ្ញាតឲ្យប្រធានកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងតំណាងខុនរ៉ាដអាដិនណៅអ៊ែរ (KAS) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាចូលជួបពិភាក្សាការងារដើម្បីត្រៀមរៀបចំកិច្ចសហប្រតិបត្តិការ និងស្វែងយល់កាន់តែច្បាស់អំពីតម្រូវការជាក់ស្តែងរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា

-អនុញ្ញាតឲ្យលោកស្រី Hai Nguyen Thi សាស្ត្រាចារ្យវេជ្ជបណ្ឌិត និងជាអតីតអនុប្រធានវិទ្យាស្ថាន Paster នៃទីក្រុងហូជីមិញ និងជាអនុប្រធានកាកបាទក្រហម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឲ្យលោក Ramil V.Khazeev តំណាងក្រុមហ៊ុន CJSC FOREIGN TRADE ដែលជាក្រុមហ៊ុនផលិត លក់ ចែកចាយគ្រឿងចក្រ និងគ្រឿងបន្លាស់គ្រប់ប្រភេទដែលមានឈ្មោះល្បីក្នុងប្រទេសរុស្សី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឲ្យលោក **ដាវ៉ារិទ្ធ គឹមយាត** នាយកវិទ្យាស្ថានសភាកម្ពុជា និងក្រុមការងារជួបពិភាក្សាការងារ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១២៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន២៤លើក ។

**៤.៣.មុខងារត្រួតពិនិត្យ**

-ជួបសវនាការជាមួយឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស្តីពីការលើកយកបញ្ហាប្រឈមនានា និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅតាមបណ្តាខេត្តមួយចំនួន ដែលគណៈកម្មការបានទទួលនៅពេលចុះបំពេញបេសកកម្មនាពេលកន្លងមក នៅទីស្តីការក្រសួងមហាផ្ទៃ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

- លោកជំទាវ **ទី បូរ៉ាស៊ី** និងឯកឧត្តម **ជា ជេដ្ឋ** អញ្ជើញចូលរួមមហាសន្និបាតលើកទី៤១ នៃសភានិយាយ ភាសាបារាំង(APF) នៅទីក្រុងBerne ប្រទេសស្វីស ។

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមសន្និសីទកំពូលស្តីពី "កាលានុវត្តភាពមុខជំនាញថ្មី នៃទស្សនវិស័យខ្សែក្រវ៉ាត់មួយ និងផ្លូវមួយរបស់សន្និសីទកំពូលនាយកប្រតិបត្តិជំនាញអាស៊ីប៉ាស៊ីហ្វិកលើកទី៣" នៅទីក្រុង Chengdu ខេត្ត Sichuan នៃសាធារណរដ្ឋប្រជាមានិតចិន ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**តេព ខុន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ